# ពិធីការសម្រាប់លីគច៍កឡាអាជីព និងការបើកកន្លែងសម្រាប់វត្ត បណ្ដុះបណ្ដាល និងព្រឹត្តការណ៍ផ្សេងៗ ដែលគ្មានអ្នកទស្សនា: ឧបសម្ព័ន្ធ S

មានប្រសិទ្ធភាព ចាប់ពីថ្ងៃសុក្រ ទី ១២ ខែមិថុនា ឆ្នាំ ២០២០

តំរូវការនានាខាងក្រោមនេះ មានលក្ខណៈជាក់លាក់ចំពោះលីគច៍កីឡារអាជីព និងទីកន្លែង ឬគ្រឹះស្ថាន។ បន្ថែមពីលើលក្ខ័ណ្ឌ ដែលបានដាក់លើលីគច៍កីឡារអាជីព ដោយមន្រ្តីសុខភាពសាធារណៈរដ្ឋ, និងពិធីការ COVID-19 ដែលយល់ព្រមដោយពលកម្ម និងការគ្រប់គ្រង, សម្ព័ន្ធ ឬលីគច៍កីឡា ក៏ត្រូវតែគោរពតាមពិធីការសុវត្ថិភាព និងការគ្រប់គ្រងការឆ្លងមេរោគរបស់និយោជិក ផងដែរ។

- ❑ លីគច៍កីឡារ ដែលប្រតិបត្តិការនូវកន្លែងលក់រាយ ត្រូវតែគោរពតាមពិធីការទិញទំនិញដោយផ្ទាល់ (ឧបសម្ព័ន្ធ B)។
- ❑ លីគច៍កីឡារ ដែលការងារមានមូលដ្ឋាននៅការិយាល័យ ត្រូវតែគោរពតាមពិធីការការិយាល័យការងារ (ឧបសម្ព័ន្ធទី G)។
- ❑ លីគច៍កីឡារ ដែលផ្ដល់នូវសម្បទាន ឬជើងជំហ៊រលក់, សេវាកម្មម្ហូបអាហារ ឬប្រតិបត្តិការភោជនីយដ្ឋាន ត្រូវតែគោរពតាមពិធីការភោជនីដ្ឋានបរិភោគខាងក្នុង (ឧបសម្ព័ន្ធ H)។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថា នឹងពិនិត្យមើលលើគេហទំព័រឡងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំ ដើម្បីទទួលបានព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក
(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា
(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង
(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន
(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

ផ្នែកសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយខណៈពេលដែលកន្លែងរបស់អ្នក អភិវឌ្ឍនូវពិធីការបើកឡើងវិញនោះ។

**លីគច័កីឡា និងកន្លែង/ស្ថាប័ន ដែលបានស្ថិតនៅក្នុងវិធានការណ៍ណែនាំខាងក្រោមនេះ ត្រូវត្រៀមជាស្រេច ដើម្បីពន្យល់ ថាតើហេតុអ្វីបានជាវិធានការណ៍ណាមួយ ដែលមិនបានត្រូវអនុវត្ត គឺមិនអាចអនុវត្តបាន ចំពោះស្ថាប័ននេះ។**

ឈ្មោះអាជីវកម្ម: ______________________

អាស័យដ្ឋានកន្លែង: ______________________

## A. នយោបាយកន្លែងធ្វើការ និងវិធានការណ៍នានា ដើម្បីការពារសុខភាពនិយោជិក (គូសទាំងអស់ដែលអនុវត្តចំពោះទីកន្លែង)

- ❑ មនុស្សគ្រប់រូបដែលអាចបំពេញភារៈកិច្ចការងាររបស់ពួកគេពីផ្ទះ ត្រូវបានគេណែនាំអោយធ្វើដូច្នេះ។
- ❑ បុគ្គលិកដែលងាយរងគ្រោះ (អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំ, អ្នកដែលមានលក្ខ័ណ្ឌសុខភាពរ៉ាំរ៉ៃ) ត្រូវបានចាត់តាំងអោយធ្វើការដែលអាចធ្វើបានពីផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន។
- ❑ ដំណើរការការងារត្រូវបានកំណត់ឡើងវិញ តាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីបង្កើនឱកាសសម្រាប់និយោជិកធ្វើការពីផ្ទះ។
- ❑ កាលវិភាគឆ្លាស់គ្នា, បន្តរបន្ទាប់គ្នា ឬប្តូរវេន ត្រូវបានបង្កើតឡើង ដើម្បីពង្រីកគំលាតឆ្ងាយរាងកាយពីគ្នា។
- ❑ និយោជិកទាំងអស់ (រាប់បញ្ចូលទាំងកីឡាករ, បុគ្គលិកបង្វឹក, បុគលិកពេទ្យ, បុគ្គលិកផ្សព្វផ្សាយ, បុគ្គលិកកន្លែង, និងបុគ្គលិកប្រតិប័ត្ត; ដែលត្រូវបានសំដៅជាសមូហភាព ថាជា "និយោជិក") ត្រូវបានគេប្រាប់ថា មិនឱ្យមកធ្វើការប្រសិនបើឈឺ ឬ, ប្រសិនបើពួកគេត្រូវបានប្រឈម នឹងអ្នកដែលមានជំងឺ COVID-19។
- ❑ ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលនិយោជិក, កីឡាករ និងអ្នកទស្សនាណាមួយ ចូលទៅក្នុងកន្លែងធ្វើការ។ ការត្រួតពិនិត្យត្រូវ តែរាប់បញ្ចូលទាំងការសួរនាំ ឬឆែកឆេរទាក់ទងទៅនឹងការក្អក, ដង្ហើមខ្លី/ដង្ហក់ ឬគ្រុនក្តៅ និងរោគសញ្ញាផ្សេងទៀត ដែលបុគ្គលិកអាចនឹងកំពុងជួបប្រទះ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់ នៅពេលមកដល់របស់បុគ្គលម្នាក់ៗ។ ការត្រួតពិនិត្យសីតុណ្ហភាព គួរតែត្រូវបានធ្វើនៅកន្លែងធ្វើការ ប្រសិនបើអាចធ្វើទៅបាន។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ នៅពេលទទួលបានដំណឹងថានិយោជិកម្នាក់ ឬច្រើននាក់ ធ្វើតេស្ដ៍វិជ្ជមាន, ឬមានរោគសញ្ញាស្របគ្នាទៅនឹងជំងឺ COVID-19 (ករណី), និយោជកត្រូវមានផែនការ ឬពិធីសារដើម្បីអោយករណីដាក់ខ្លួនគេអោយនៅឯកោនៅផ្ទះ ហើយតម្រូវអោយមានការដាក់អោយនៅឃ្លាតដាច់ឆ្ងាយពីគេខ្លួនឯងភ្លាមៗចំពោះ ឬនៃនិយោជិកទាំងអស់ ដែលមានការប្រឈមនៅនឹងកន្លែងធ្វើការ ទៅនឹងករណី។ ផែនការរបស់និយោជក គួរតែពិចារណាលើពិធីការសម្រាប់និយោជិកដែលបានដាក់ខ្លួនអោយនៅឃ្លាតដាច់ឆ្ងាយពី គេទាំងអស់មានលទ្ធភាពធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សំរាប់ជំងឺ COVID-19 ដើម្បីកំណត់ថា តើមានការប្រឈមនៅកន្លែងធ្វើការបន្ថែមទៀត, ដែលអាចតម្រូវឱ្យមានវិធានការណ៍ត្រួតពិនិត្យជំងឺ COVID-19 បន្ថែម។
- ❑ និយោជិកនិងកីឡាករទាំងអស់ ត្រូវបានផ្តល់ជូន, ដោយឥតគិតថ្លៃ, នូវគម្របមុខ។ គម្របមុខ គឺត្រូវពាក់ដោយនិយោជិកគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ នៅពេលមានការប៉ះពាល់ ឬទំនងជាទាក់ទងជាមួយអ្នកដទៃ, លើកលែងតែ ក្នុងអំឡុងពេលសកម្មភាពរាងកាយ, ការអនុវត្តន៍, និងហ្គេម, កីឡាករ អាចនៅតែគ្មានម៉ាស់។
- ❑ ក្នុងករណីដែលមានករណីចំនួន ៣ ឬច្រើនជាងនេះ ត្រូវបានរកឃើញនៅក្នុងកន្លែងធ្វើការក្នុងរយៈពេល ១៤ ថ្ងៃ និយោជកគួរតែរាយការណ៍ពីចង្កោមហេតុការណ៍នេះ ទៅមន្ទីរសុខាភិបាល និងសេវាមនុស្សនៃទីក្រុងឡុងប៊ិច តាមលេខ ៥៦២-៥៧0-INFO
- ❑ និយោជិកត្រូវបានណែនាំ អោយលាងសំអាតគម្របមុខរបស់ពួកគេជារៀងរាល់ថ្ងៃ។
- ❑ ស្ថានីយការងារណាមួយ នៅក្នុងកន្លែងនេះ ត្រូវបានបំបែកដោយចម្ងាយយ៉ាងតិចប្រាំមួយហ្វីត។
- ❑ ពិចារណាលើការធ្វើតេស្ដ៍តាមកាលកំណត់របស់និយោជិក និងកីឡាករ, អោយបានសមស្រប, ដើម្បីកាត់បន្ថយហានិភ័យនៃការរីករាលដាលនៃជំងឺ COVID-19។ និយោជកទទួលខុសត្រូវ ក្នុងការផ្តល់ការធ្វើតេស្តដោយមិនគិតថ្លៃ ដល់និយោជិក និងកីឡាករ។
- ❑ ក្រុមនានាបានដាក់ផែនការជាក់លាក់សម្រាប់កន្លែង សម្រាប់រៀបចំព្រឹត្តិការណ៍កីឡាដោយគ្មានអ្នកទស្សនា ទៅកាន់មន្ទីរសុខាភិបាល និងសេវាមនុស្សឡុងប៊ីឆ យ៉ាងតិច ២ សប្តាហ៍ មុនពេលរៀបចំព្រឹត្តិការណ៍នានា បែបនេះ។
- ❑ បន្ទប់ឡុកឃើ, បន្ទប់ថ្លឹងទំងន់, បន្ទប់បណ្តុះបណ្តាល, បន្ទប់ទឹក និងកន្លែងទូទៅផ្សេងទៀត កំពុងត្រូវបានគេសំឡាប់មេរោគជាញឹកញាប់, តាមកាលវិភាគដូចខាង ក្រោមៈ
    - ○ បន្ទប់ឡុកឃើ ______________________________
    - ○ បន្ទប់ថ្លឹងទំងន់ ______________________________
    - ○ បន្ទប់បណ្តុះបណ្តាល ______________________________
    - ○ បន្ទប់ទឹក ______________________________
    - ○ ផ្សេងៗ ______________________________
- ❑ ថ្នាំសំឡាប់មេរោគ និងគ្រឿងផ្គត់ផ្គង់នានា សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖

______________________________________________________________

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ ទឹកលាងដៃសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 សំរាប់និយោជិកទាំងអស់ អាចរកបានតាម ទីតាំងនានា ដូចខាងក្រោម៖

________________________________________________

- ❑ និយោជិកត្រូវបានតំរូវអោយ និងអនុញ្ញាតិអោយមានពេលវេលាគ្រប់គ្រាន់ សម្រាប់លាងដៃរបស់ពួកគេ យ៉ាងហោចណាស់រៀងរាល់ ៣០ នាទីម្តង ឬនៅពេលដែលមានតំរូវការ ប្រសិនបើស្រោមដៃបានត្រូវផ្តល់អោយ។ នៅកន្លែង ដែលការលាងដៃ គឺមិនអាចអនុវត្តបាន, ទឹកធ្វើអនាម័យដៃ ដែលមានជាតិអាល់កុលយ៉ាងហោចណាស់ ៦០% ត្រូវបានផ្តល់ទៅដល់និយោជិកជំនួសវិញ។
- ❑ ច្បាប់ថតចំលងពិធីសារនេះ ត្រូវបានចែកចាយដល់និយោជិកម្នាក់ៗ។
- ❑ កម្មករម្នាក់ៗ ត្រូវបានចាត់ចែងគ្រឿងបរិក្ខារផ្ទាល់ខ្លួន ហើយកំណត់កន្លែងធ្វើការ តាមលទ្ធភាពដែលអាចធ្វើទៅបាន។ តំរូវការសំរាប់ការចែករំលែករបស់របរ ដែលបានយកទៅទុក ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- ❑ របស់របរផ្ទាល់ខ្លួន (ឧទាហរណ៍, ដបទឹក, កន្សែង, ឯកសណ្ឋាន ។ល។) មិនត្រូវបានចែកចាយឡើយ។
- ❑ ស្រេចលើចិត្ត — ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត:

________________________________________________

## B. គោលការណ៍នានា ដើម្បីធានាបាននូវគំលាតឆ្ងាយរាងកាយពីគ្នា

- ❑ ចំនួនមនុស្សនៅក្នុងបន្ទប់ណាមួយនៅក្នុងកន្លែង (ឧទាហរណ៍, បន្ទប់ប្រជុំ, បន្ទប់ថ្លឹងទំងន់, តុលាការ, ហាងកាហ្វេ, កន្លែងហាត់ប្រាណ, ។ល។) ត្រូវកំរឹតរាល់ពេល ដូចជាមនុស្សទាំងអស់នៅក្នុងបន្ទប់ អាចរក្សាយ៉ាងតិចណាស់ ៦ ហ្វីត ចម្ងាយពីម្នាក់ទៅម្នាក់ទៀត នៅគ្រប់ពេលដែលអាចអនុវត្តបាន ឬចម្ងាយ ៨ ហ្វីត ប្រសិនបើពួកគេ មានការពាក់ព័ន្ធឬចូលរួមក្នុងសកម្មភាពរាងកាយ។
- ❑ ការចូលទៅកាន់ទីតាំងនេះត្រូវបានកំណត់ចំពោះអ្នកដែលជានិយោជិកចាំបាច់, ហើយបើអាចធ្វើទៅបាន, និយោជិកចាំបាច់ ត្រូវបានកំរឹតនៅតាមតំបន់មួយចំនួននៅក្នុងកន្លែង/គ្រឹះស្ថាន ដោយផ្អែកលើភារៈកិច្ច និងការទទួលខុសត្រូវរបស់ពួកគេ។
- ❑ ក្រុមរក្សាកំណត់ហេតុទីតាំងលម្អិត ដែលកត់ត្រាបញ្ជីបុគ្គលទាំងអស់ ដែលមានវត្តមាននៅឯក្រុមការងារនៅថ្ងៃដែលបានផ្តល់ឱ្យ, រួមមានឈ្មោះរបស់មនុស្ស និងព័ត៌មានទំនាក់ទំនង, រាប់បញ្ចូលទាំងលេខទូរស័ព្ទ និងអាស័យដ្ឋានអ៊ីម៉ែល។
- ❑ អ្នកទស្សនាទៅកាន់ទីតាំងនេះ មិនត្រូវបានអនុញ្ញាតិអោយឡើយ តាមលទ្ធភាពដែលអាចធ្វើទៅបាន, ប៉ុន្តែប្រសិនបើភ្ញៀវត្រូវតែអនុញ្ញាតិអោយចូល, ក្រុមនោះមានកំណត់ត្រាឈ្មោះ និងព័ត៌មានទំនាក់ទំនង របស់អ្នកទស្សនារួមទាំង

លេខទូរស័ព្ទ និងអាស័យដ្ឋានអ៊ីម៉ែល ដែលមាននៅក្នុងកំណត់ហេតុកន្លែង។

- ❑ កីឡាករ, គ្រូបង្វឹក, បុគ្គលិកបណ្តុះបណ្តាល និងបុគ្គលិកដទៃទៀត, ត្រូវបានណែនាំឱ្យរក្សាចម្ងាយយ៉ាងតិចប្រាំមួយ (៦) ហ្វីត ពីគ្នាទៅវិញទៅមកគ្រប់ពេល។ នៅពេលដែលកីឡាករ កំពុងចូលរួមក្នុងសកម្មភាពរាងកាយ (ឧទាហរណ៍, ក្នុងអំឡុងពេលហាត់ប្រាណ និងហ្វឹកហាត់, ។ល។), កីឡាករត្រូវមានចម្ងាយយ៉ាងតិច ៨ ហ្វីត ពីនិយោជិកផ្សេងទៀត នៅពេលណាដែលអាចធ្វើទៅបាន។
- ❑ បឺទបង់ស្អិត ឬដាក់សញ្ញាសម្គាល់ផ្សេងទៀត ជួយដល់កីឡាករ និងនិយោជិកក្នុងការរក្សាចម្ងាយឆ្ងាយរាងកាយពីគ្នាឱ្យបានសមរម្យ។
- ❑ ស្ថានីយ៍ការងាររបស់និយោជិកណាមួយ នៅក្នុងកន្លែង ឬគ្រឹះស្ថាន ត្រូវបានបំបែកគ្នាយ៉ាងតិច ៦ ហ្វីត និងកន្លែងរួមត្រូវបានកំណត់ដើម្បីកំណត់ការប្រមូលផ្តុំបុគ្គលិក ឬកីឡាករ និងដើម្បីធានាឱ្យមានចម្ងាយឆ្ងាយរាងកាយពីគ្នា យ៉ាងតិច ៦ ហ្វីត។
- ❑ តាមលទ្ធភាពដែលអាចធ្វើទៅបាន, ទីតាំងក្រុមត្រូវ បានត្រូវរៀបចំឡើងវិញ ដើម្បីកាត់បន្ថយកីឡាករ និងនិយោជិកផ្សេងទៀត ដែលទាក់ទងគ្នាទៅវិញទៅមក ពេលធ្វើដំណើរឆ្លងកាត់កន្លែងនេះ (ឧទាហរណ៍, បើកផ្លូវតែមួយផ្លូវប៉ុណ្ណោះ ដែលមានផ្លាកសញ្ញាចង្អុលបង្ហាញទេសដៅ, កំណត់ទ្វារដែលថា ជា "ច្រកចូល" ឬ "ចេញ" តែប៉ុណ្ណោះ, និងកំណត់ជណ្តើរថា ជា "ឡើងលើ" ឬ "ចុះក្រោម")។
- ❑ ក្នុងកំឡុងពេលបណ្តុះបណ្តាលទំងន់ ឬការហាត់ប្រាណ, កីឡាករនៅតែរក្សាអោយមានចម្ងាយ ៨ ហ្វីត ពីគ្នា។ តាមដែលអាចធ្វើទៅបាន, បុគ្គលិកបណ្តុះបណ្តាលរក្សាអោយមានចម្ងាយយ៉ាងតិច ៦ ហ្វីត ពីគ្នា និង ៨ ហ្វីត ពីកីឡាករ ក្នុងអំឡុងពេលហ្វឹកហាត់ និងហាត់ប្រាណរាងកាយ។ និយោជិកអាចចូលមកជិតម្តងម្កាល នៅពេលចាំបាច់ក្នុងកំឡុងពេលព្យាបាល ឬពេលហាត់ទំងន់។
- ❑ ក្នុងអំឡុងពេលអនុវត្ត ឬបណ្តុះបណ្តាល/ហ្វឹកហាត់, កីឡាករ មានចម្ងាយឃ្លាតឆ្ងាយរាងកាយពីគ្នា បានគ្រប់គ្រាន់ និងពីអ្នកដ៏ទៃ នៅពេលណាដែលអាចធ្វើទៅបាន។
- ❑ តាមលទ្ធភាពដែលអាចធ្វើទៅបាន, ការអនុវត្តក្រុមត្រូវបានធ្វើឡើង ដូចជាកាត់បន្ថយទំនាក់ទំនងរាងកាយ រវាងកីឡាករ និងអ្នកដទៃទៀត។
- ❑ ក្នុងកំឡុងពេលនៃការប្រកួតអនុវត្តជាក់ស្តែង ក្នុងក្រុម, ការកាន់កាប់កន្លែង/គ្រឹះស្ថាន ត្រូវបានកំណត់ចំពោះនិយោជិកដែលចាំបាច់។
- ❑ ក្នុងកំឡុងពេលហ្គេមដែលមិនមានអ្នកទស្សនា, ការកាន់កាប់កន្លែងត្រូវបានកំណត់ ចំពោះអ្នកដែលចាំបាច់ សម្រាប់ប្រតិបត្តិការថ្ងៃហ្គេម (ឧទាហរណ៍, ក្រុមផ្សាយ TV/ វិទ្យុ, ក្រុមអ្នករៀបចំព្រឹត្តិការណ៍/ប្រតិបត្តិការ, គ្រូបង្វឹក, ក្រុមបុគ្គលិកពេទ្យ, អត្តពលិក។ល។ ) ហើយប្រសិនបើអាចធ្វើទៅបាន មិនអាចលើសពី ៣០០ នាក់ឡើយ។ តាមលទ្ធភាព

ដែលអាចធ្វើទៅបាន, បុគ្គលគ្រប់រូបដែលបានអនុញ្ញាតិអោយចូលទៅក្នុងមណ្ឌល/កន្លែងនេះ ត្រូវបានណែនាំឱ្យរក្សាចម្ងាយឃ្លាតឆ្ងាយរាងកាយពីគ្នាយ៉ាងតិច ៦ ហ្វីត ហើយការចូលទៅកាន់ទីតាំងត្រូវបានកំរឹត នៅតំបន់ជាក់លាក់។

- ❑ បឹទបង់ស្ទីត ឬដាក់សញ្ញាសម្គាល់ផ្សេងទៀត ជួយដល់កីឡាករ និងនិយោជិកក្នុងការរក្សាចម្ងាយឆ្ងាយរាងកាយពីគ្នាឱ្យបានសមរម្យ។
- ❑ ក្នុងកំឡុងពេលលេងហ្គេម, កន្លែងដែលកីឡាករ អង្គុយក្រៅតារាង (ឧទាហរណ៍, កីឡាករបម្រុង, កន្លែងជ្រកម្លប់មុនចូលលេង, កំដៅសាច់ដុំមុនចូលលេង) ត្រូវបានរៀបចំឡើង ដើម្បីបង្កើតកន្លែងអង្គុយបន្ថែម ក្នុងន័យដែលកីឡាករ និងនិយោជិក អាចរក្សាចម្ងាយរាងកាយឆ្ងាយពីគ្នាបាន ៦ ហ្វីត។
- ❑ ស្ថានីយ៍ការងាររបស់និយោជិកណាមួយ នៅក្នុងកន្លែង/គ្រឹះស្ថាន ត្រូវបានបំបែកគ្នាយ៉ាងតិច ៦ ហ្វីត និងកន្លែងរួមនៅក្នុងអាគារ ត្រូវបានរៀបចំសារឡើងវិញ ដើម្បីកំរឹតការប្រមូលផ្តុំនិយោជិក ឬកីឡាករ និងដើម្បីធានាបាននូវចម្ងាយរាងកាយឆ្ងាយពីគ្នា យ៉ាងតិច ៦ ហ្វីត។
- ❑ ក្នុងកំរឹតដែលអាចធ្វើបាន, រៀបចំកន្លែងចតយានយន្តបន្តរបន្ទាប់គ្នា នៅចំណតរថយន្ត និងយានដ្ឋាន ដូចជាបង្កើតចម្ងាយរវាងឡាន (ឧទាហរណ៍, ចន្លោះទំនេររវាងកន្លែងចន្លោះ ដែលបានកាន់កាប់នីមួយៗ)។

## C. វិធានការណ៍នានា សំរាប់គ្រប់គ្រងការឆ្លង

- ❑ ប្រព័ន្ធ HVAC ដំណើរការល្អ, នៅដំណើរការ; ដល់កម្រិតអតិបរិមាដែលអាចធ្វើទៅបាន, ខ្យល់ត្រូវបានបន្ថែម ឬកើនឡើង។ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់ ដែលមានប្រសិទ្ធិភាពខ្ពស់, ធ្វើឱ្យប្រសើរឡើងនូវតម្រងខ្យល់របស់អាគារឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុត តាមតែអាចធ្វើទៅបាន, បើកបង្អួច និងទ្វារ, និងធ្វើការកែប្រែផ្សេងទៀត ដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់នៅក្នុងការិយាល័យ និងកន្លែងផ្សេងទៀត។
- ❑ តំបន់រួម និងវត្ថុផ្សេងៗដែលប៉ះពាល់ជាញឹកញាប់ (ឧទាហរណ៍, តុ, ប្រដាប់កាន់ទ្វារ ឬដៃទ្វា, កុងតាក់បើកភ្លើង) ត្រូវបានរំងាប់មេរោគ ក្នុងមួយម៉ោងម្តង ក្នុងពេលម៉ោងធ្វើការ ដោយប្រើឧបករណ៍រំងាប់មេរោគ ដែលបានអនុម័តដោយ EPA និងធ្វើតាមការណែនាំរបស់អ្នកផលិត សម្រាប់ការប្រើប្រាស់។
- ❑ ហ្វីតណេស, ការហ្វឹកហាត់ និងវត្ថុទំងន់ ត្រូវបានកំណត់ដើម្បីកំណត់ចំនួនបុគ្គល នៅក្នុងបន្ទប់ នៅពេលណាមួយម្តង និងអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់រវាងវគ្គ (យ៉ាងហោចណាស់ ៣០ នាទី) សម្រាប់ការរំងាប់មេរោគបន្ទប់ យ៉ាងហ្មត់ចត់ រវាងវគ្គនីមួយៗ។
- ❑ ការព្យាបាល (ឧទាហរណ៍, ការព្យាបាលដោយចលនា ឬម៉ាស្សា) ត្រូវបានអនុញ្ញាតិអោយធ្វើអន្តរាគមន៍ព្យាបាលជាបន្ទាន់។ គ្រូបណ្តុះបណ្តាលអត្តពលកម្ម ធ្វើការជាមួយកីឡាករ ដើម្បីកំណត់ជម្រើសផ្សេងៗក្នុងការប៉ះដោយផ្ទាល់

សម្រាប់ការគ្រប់គ្រងរបួស។

- ❑ រាល់ឧបករណ៍អនុវត្តទាំងអស់ (ឧទាហរណ៍, បាល់) និងឧបករណ៍ហ្វឹតណេស (ឧទាហរណ៍, ប្រដាប់បង្វិលស្មោ, បន្ទប់ទំងន់ និងឧបករណ៍សំរាប់ហាត់ប្រាណ) ត្រូវបានរំងាប់មេរោគយ៉ាងហ្មត់ចត់ រវាងកីឡាករ, ឬក្នុងកំរិតដែលអាចធ្វើទៅបាន, មិនត្រូវបានចែករំលែក ក្នុងចំណោមកីឡាករឡើយ។
- ❑ តាមលទ្ធភាពដែលអាចធ្វើទៅបាន, ឧបករណ៍ហ្គេមទាំងអស់ (ឧទាហរណ៍, បាល់, ប្រចៀវ) ត្រូវបានរំងាប់មេរោគជាប្រចាំ ឬដូរជំនួសជាប្រចាំ ក្នុងកំឡុងពេលហ្គេម។
- ❑ កីឡាករ, គ្រូបង្វឹក និងនិយោជិក ត្រូវបានលើកទឹកចិត្តមិនឱ្យធ្វើទំនាក់ទំនងរាងកាយ ដែលមិនចាំបាច់ជាមួយគ្នានោះឡើយ (ឧទាហរណ៍, ទះដៃហាយហ្វាយ, ចាប់ដៃ, បុកកណ្តាប់ដៃគ្នា ។ល។ )។
- ❑ កន្លែងទាំងមូល (បន្ទប់ឡកឃើ, បន្ទប់វេជ្ជសាស្រ្ត, បន្ទប់ហ្វឹតណេស, បន្ទប់ទំងន់, ។ល។) ត្រូវបានសម្អាតយ៉ាងហោចណាស់ជារៀងរាល់ថ្ងៃ, ឬរវាងក្រុមបណ្តុះបណ្តាលផ្សេងៗគ្នា; បន្ទប់ទឹក និងកន្លែង/វត្ថុ ដែលបានប៉ះជាញឹកញាប់ ត្រូវបានសម្អាតឱ្យបានញឹកញាប់ នៅពេលដែលកន្លែងកំពុងប្រើប្រាស់។
- ❑ មានទឹកធ្វើអនាម័យដៃ, ក្រដាស់ស្តើង និងធុងសំរាម ផ្តល់អោយនិយោជិកនៅឯ ឬក្បែរច្រកចូលទៅកាន់កន្លែង ឬគ្រឹះស្ថាន។

## D. វិធានការណ៍នានា ដែលទំនាក់ទំនងទៅកាន់សាធារណៈជន

- ❑ ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានបិទផ្សាយនៅតាមច្រកចូលទាំងអស់។
- ❑ ស្លាកសញ្ញាត្រូវបានបឹទផ្សាយ ដែលជូនដំណឹងដល់សាធារណៈជនថា គ្មានការចូលប្រើប្រាស់ជាសាធារណៈនៅទីតាំងនេះទេ ហើយថាសាធារណៈជន មិនគួរប្រមូលផ្តុំនៅខាងក្រៅកន្លែងនោះទេ។ តាមលទ្ធភាពដែលអាចធ្វើទៅបាន, បុគ្គលិកសន្តិសុខទំលាក់ទឹកចិត្ត ឬរាំងយ៉ាងសកម្ម មិនឱ្យសាធារណៈជនចូលទៅក្នុងផ្ទាល់ ឬនៅជុំវិញ បរិវេណកន្លែង/គ្រឹះស្ថាន នេះឡើយ។

## E. វិធានការណ៍នានា ដែលធានានូវការទទួលបានសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

- ❑ មិនបើកអោយសាធារណៈចូលទេ, មិនអាចអនុវត្តនឡើយ នៅពេលនេះទេ។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីមែល: CETASKFORCE@LONGBEACH.GOV**

វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់វាយនៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។

អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:

ឈ្មោះទំនាក់ទំនងអាជីវកម្ម: ______________________________

លេខទូរស័ព្ទ: ______________________________

កាលបរិច្ឆេទកែប្រែចុងក្រោយ: ______________________________

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**